ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
# កំពង់ត្រឡាច

សម្រាប់រយៈពេល ០៣ ឆ្នាំ

(ខែមីនា ឆ្នាំ២០២១ - ខែមីនា ២០២៣)

| | |
|---|---|
| សហគមន៍នេសាទ | : កំពង់ត្រឡាច |
| ភូមិ | : កំពង់ត្រឡាច |
| សង្កាត់ | : ព្រៃធំ |
| ក្រុង | : កែប |
| ខេត្ត | : កែប |

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ កំពង់ត្រឡាច

សម្រាប់រយៈពេល ០៣ ឆ្នាំ

(ខែមីនា ឆ្នាំ២០២១ - ខែមីនា ២០២៣)

សហគមន៍នេសាទ : កំពង់ត្រឡាច

ភូមិ : កំពង់ត្រឡាច

សង្កាត់ : ព្រៃធំ

ក្រុង : កែប

ខេត្ត : កែប

## ១-ស្ថានភាពទូទៅ

សហគមន៍នេសាទកំពង់ត្រឡាចត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ២០១០ ដោយមានការសម្របសម្រួលរៀបចំពីរដ្ឋបាលជលផល សហការជាមួយខណ្ឌរដ្ឋបាលជលផល និងអាជ្ញាធរមូលដ្ឋាន ។

ចាប់តាំងពីបង្កើតសហគមន៍នេសាទរហូតមកដល់សព្វថ្ងៃ សហគមន៍នេសាទយើងខ្ញុំ បានខិតខំប្រឹងប្រែងធ្វើការងារសំខាន់ៗជាច្រើនដូចជា រៀបចំលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង បញ្ជីរឈ្មោះគណៈកម្មការ បញ្ជីរឈ្មោះសមាជិក កិច្ចព្រមព្រៀង ផែនទីកន្លែងនេសាទសហគមន៍ និងការងារទប់ស្កាត់បង្រ្កាបបទល្មើសជលផលនិងផ្សព្វផ្សាយដោយបានសហការជាមួយជំនាញជលផល និងអាជ្ញាធរមូលដ្ឋាន ។

## ២-អំពីប្រជាសាស្រ្ត និងសេដ្ឋកិច្ចសង្គម

ក -ប្រជាសាស្រ្ត

-ចំនួនប្រជាពលរដ្ឋសរុបនៅក្នុងសហគមន៍មានចំនួន ៥៧០ គ្រួសារ មនុស្សសរុបចំនួន២១១៩ នាក់ ស្រីចំនួន ១០៥០ នាក់ ក្នុងនោះមាន ៖

-ជនពិការចំនួន២១នាក់ ស្រី១២នាក់

-ចាស់ជរា ១០៤នាក់ ស្រី៣៣នាក់

-កុមារកំព្រា ០នាក់

-អ្នកកាន់សាសនា ព្រះពុទ្ធ ១០០%

-អ្នកមិនចេះអក្សរ ០ នាក់

-កម្រិតមត្តេយ្យចំនួន ៤៥នាក់ ស្រី២៦នាក់

-កម្រិតបឋមចំនួន១១៩នាក់ ស្រី១៣៤នាក់

-អនុវិទ្យាល័យចំនួន៨០នាក់ ស្រី៤៨នាក់

-វិទ្យាល័យសរុប១៩០នាក់ ស្រី៦៨នាក់

-មហាវិទ្យាល័យ ៥២នាក់ ស្រី២១នាក់

ខ-មុខរបរ

មុខរបរសំខាន់ៗរបស់ប្រជាពលរដ្ឋក្នុងសហគមន៍នេះរួមមាន៖

-ធ្វើនេសាទចំនួន៨១ គ្រួសារ

-ធ្វើស្រែចំនួន២៨៨ គ្រួសារ

-ដាំបន្លែចំនួន៧២ គ្រួសារ

-លក់ដូចំនួន០៣ គ្រួសារ

-ចិញ្ចឹមសត្វចំនួន៥១៣ គ្រួសារ

-កម្មករចំនួន៦០ គ្រួសារ

-ចំណាកស្រុកនៅក្នុងប្រទេស១០១ គ្រួសារ

-ចំណាកស្រុកក្រៅប្រទេសចំនួន២៥ គ្រួសារ

## ៣-កន្លែងនេសាទសហគមន៍ និងធនធានដែលមាននៅក្នុងដែននេសាទសហគមន៍

ក-ទីតាំង

កន្លែងនេសាទសហគមន៍កំពង់ត្រឡាចជាដែននេសាទតំបន់ឆ្នេរសមុទ្រមានទំហំ ៤២២ ហិកតា និងមានកំណត់និយាមការដូចមានចែងនៅក្នុងកិច្ចព្រមព្រៀង។

មានព្រំប្រទល់៖

-ខាងជើងទល់នឹងសហគមន៍នេសាទអូរក្រសារ

-ខាងត្បូងទល់នឹងសហគមន៍នេសាទភូមិថ្មី

-ខាងកើតទល់នឹងស្រែអំបិល

-ខាងលិចទល់នឹងសមុទ្រ

**ខ-ដែននេសាទ**

កន្លែងនេសាទសហគមន៍កំពង់ត្រឡាច ជាដែននេសាទតំបន់ឆ្នេរ ។

នៅតាមដែននេសាទសហគមន៍ប្រជាពលរដ្ឋទៅរកនេសាទដោយប្រើប្រាស់ឧបករណ៍នេសាទ និងរដូវនេសាទ ដូចខាងក្រោម :

១.លបក្ដាម ១២ខែ

២.មងក្បក ខែមករា-ខែឧសភា

៣.មងក្ដាម ១២ខែ

៤.ឈិបរុញដៃ ខែមេសា-ខែកក្កដា

៥.សន្ទូចអូសមឹក ខែមិថុនា-ខែវិច្ឆិកា

៦.សំណាញ់ ១២ខែ

៧.ចាប់ក្ដាម បង្គា ដោយដៃ ខែមករា-ខែមិថុនា

៨.មងត្រីផ្ទោង ១២ខែ

**គ-ធនធានជលផល**

-**ប្រភេទត្រីសមុទ្រ ៖** ត្រីស ត្រីក្បាលហែង ត្រីក្អកស ត្រីអាំងកើយ ត្រីបេកា ត្រីតុកកែ ត្រីចាប ត្រីអង្រៃ ត្រីកិ ត្រីពួច ត្រីចង្កូមបី ត្រីក្ដចិន ត្រីក្បក ត្រីកាម៉ុង ត្រីម្រេច ត្រីស្លង់ ត្រីផ្ទោង ត្រីឆ្លាម ត្រីប្រលួស ត្រីក្អុក ត្រីក្អុកក្បាលស្រួច ត្រីអាម៉ក់ ត្រីបបែល ត្រីអណ្ដាតឆ្កែ ត្រីអួយ ត្រីកន្ទុយក្រហម ត្រីអង្រៃ ត្រីកន្ទុយបី ត្រីឆ្មារ ត្រីកំពត ត្រីខែ ត្រីគោ ត្រីសមុទ្រទៃ ត្រីប្រកង ត្រីចាបស ត្រីចាបខ្មៅ ត្រីការ៉ាវ ត្រីត្រចៀកដំរី ត្រីដូអង្គរ ត្រីផ្ទុកសមុទ្រ ត្រីអណ្ដែងប៉ុយ ត្រីប្រម៉ា ត្រីកន្ទុយក្របី ត្រីកន្ដាំង ត្រីស្លឹកឫស្សី ត្រីកន្ទុយរឹង ត្រីអណ្ដែងខ្លុយ ........។ល។

-**ប្រភេទវារីសត្វ ៖** បង្គា ក្ដាមសេះ ក្ដាមថ្ម ក្ដាមជំរ ក្ដាមព្រលិត ក្ដាមផ្ដលាន់ អន្ទុងសមុទ្រ មឹក បង្កងកណ្ដូប ខ្យងត្របួន ខ្យងកំបោរ ខ្យងចាក់ព្រែង ខ្យងភ្នែកប្រើស ខ្យងដែកគោល ខ្យងត្នោត ខ្យងដូង ខ្យងដីរំ ខ្យងចំពុះទា ខ្យងផ្លិត ខ្យងចបជីក ខ្យងបន្លា ខ្យងផ្ញើប្រាណ ខ្យងវៀចមាត់ ខ្យងតាឱត ងាវភក់ គ្រំក្រឡាហួល ងាវគ្រែងឈាម បង្កងប៉ាក អន្ទង់ ខ្ទីង និងប្រភេទសត្វជិតផុតពូជ ( គ្រំយក្ស កញ្ឆ ផ្សោតខ្មៅ ផ្សោតប៉ារ៉ា បង្គ្រប ) ។ល។

**៤-ការធ្វើនេសាទ**

**ក-អ្នកនេសាទ**

-អ្នកនេសាទជាសមាជិកសហគមន៍ ចំនួន១១៦ នាក់ ស្រី២១ នាក់

-អ្នកនេសាទមិនមែនជាសមាជិកសហគមន៍នេសាទ នៅក្នុងសហគមន៍ចំនួន២០០៣ គ្រួសារ

-ប៉ាន់ស្មានអ្នកនេសាទមិនមែនជាសមាជិកដែលមកពីខាងក្រៅសហគមន៍មានចំនួន១២ នាក់ (១២គ្រួសារ)

**ខ-ឧបករណ៍នេសាទ**

-ឧបករណ៍នេសាទ និងទូកកាណូតរបស់សមាជិកសហគមន៍នេសាទ

**ឧបករណ៍នេសាទសមុទ្រ ៖**

ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ត្រូវបានរៀបចំឡើងដូចខាងក្រោម ៖

| ឈ្មោះ/ទីតាំងកន្លែងនេសាទ | ពេលវេលាធ្វើនេសាទ | ឧបករណ៍នេសាទអនុញ្ញាតឱ្យប្រើ | | | ផ្សេងៗ |
|---|---|---|---|---|---|
| | | ប្រភេទ | ទំហំ/ប្រវែង | ចំនួន | |
| ដែននេសាទកំពង់ក្រឡាច | ពេញ ១ ឆ្នាំ | មងក្តាម | ក្រឡា៦ ស.ម ឡើង/៣០០ម៉ែត្រ | ០២ គ្រួសារ | |
| | ពេញ ១ ឆ្នាំ | លបក្តាម | ក្រឡា០.៤x០.៣ម ឡើង/២០០ លប | ១៣ គ្រួសារ | |
| | ខែមករា-ឧសភា | មងត្រីក្បក | ក្រឡា៣,៥ស.មx៤ ស.ម/១០០ ម៉ែត្រ | ៣០ គ្រួសារ | |
| | ខែមេសា ដល់ ខែកក្កដា | ឈិបរុញដៃ | ៤មx៥ម/១គ្រឿង | ១០ គ្រួសារ | |
| | ខែវិច្ឆិកា ដល់ ខែមិថុនា | សន្ទូចអួសមឹក | ១០០ផ្លែ | ០៥ គ្រួសារ | |
| | ពេញ១ឆ្នាំ | សំណាញ់ | ៦ម | ០២ គ្រួសារ | |
| | ខែមករា ដល់ ខែមិថុនា | ចាប់ក្តាម បង្គា ត្រីដោយដៃ | | ៣០ គ្រួសារ | |
| | ពេញ១ឆ្នាំ | មងផ្ទោង | ០.២ស.ម/១០០ម | ០៣ គ្រួសារ | |

**ទូកកាណូតរបស់សមាជិក៖**

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| ទូកចែវ | ០២ គ្រឿង | ៣០០ គីឡូក្រាម | |
| ទូកមានម៉ាស៊ីនបន្ដើត | ១៤ គ្រឿង | ១,០០០ ទៅ ១,៥០០ គីឡូក្រាម | ៦សេះ-១៨ សេះ |
| ទូកមានម៉ាស៊ីនបាត | ០ គ្រឿង | | |

**-ឧបករណ៍នេសាទ និងទូកកាណូតរបស់អ្នកមិនមែនជាសមាជិកសហគមន៍ដែលមកពីខាងក្រៅសហគមន៍នេសាទ**

| ប្រភេទឧបករណ៍ | ឯកតា | ចំនួន | ទំហំ/ប្រវែង |
|---|---|---|---|
| មងក្តាម | ម៉ែត្រ | ៧ទូក | ១ទូក=៤០០ម៉ែត្រ/ ក្រឡា៦ស.ម ឡើង |
| មងបង្គា | ម៉ែត្រ | ៣០ទូក-៥០ទូក | ១ទូក=៤២០ម៉ែត្រ/ ក្រឡា៣,៨ស.ម |
| លបក្តាម | លប | ៧ទូក | ១ទូក=២០០ លប/ ក្រឡា៦ ស.ម ឡើង |

**-ទូកកាណូត**

| ប្រភេទទូក កាណូត | ចំនួនគ្រួសារ | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| ទូកមានម៉ាស៊ីនបណ្តើត | ១២ គ្រឿង | ១,០០០ ទៅ ១,៥០០ គីឡូក្រាម | ៦សេះ-១៨ សេះ |

គ-ការប៉ាន់ប្រមាណផលចាប់បានប្រចាំឆ្នាំ

| ប្រភេទផលនេសាទ | បរិមាណផលនេសាទចាប់បានគិតជាមធ្យមប្រចាំគ្រួសារ(គិតជាគីឡូក្រាម) | | |
|---|---|---|---|
| | រដូវប្រាំង | រដូវវស្សា | សរុបប្រចាំឆ្នាំ |
| បង្គា | ៤០០គីឡូក្រាម | ៣០០គីឡូក្រាម | ៧០០គីឡូក្រាម |
| ក្តាម | ៦០០គីឡូក្រាម | ៥០០គីឡូក្រាម | ១១០០គីឡូក្រាម |
| មឹក | ៣០០គីឡូក្រាម | ១២០គីឡូក្រាម | ៤២០គីឡូក្រាម |
| ត្រីចំរុះ | ៤០០គីឡូក្រាម | ៣០០គីឡូក្រាម | ៧០០គីឡូក្រាម |

## ៥-ផែនការគ្រប់គ្រងសហគមន៍នេសាទ

### ក-ទស្សនៈវិស័យ

សហគមន៍នេសាទកំពង់ត្រឡាច មានទស្សនៈវិស័យរួមចំណែកគ្រប់គ្រងធនធានជលផលប្រកបដោយសមធម៌ និងចីរភាព ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

### ខ-គោលបំណង

-ចូលរួមគ្រប់គ្រងដែននេសាទ កន្លែងនេសាទគ្រួសារ ដែលរក្សាទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាប្រពៃណី ឬ សហគមន៍ធ្វើនេសាទ កន្លែងនេសាទបំរុង និងកន្លែងនេសាទតាមឆ្នេរ។

-ចូលរួមគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តភាព និងធានាការបែងចែកផលប្រយោជន៍ធនធានជលផល ជូនប្រជាពលរដ្ឋខ្មែរប្រកបដោយសមធម៌ ។

-ដើម្បីធ្វើឱ្យប្រសើរឡើងនូវជីវភាពសមាជិកសហគមន៍ តាមរយៈការអភិវឌ្ឍន៍ចំរុះដោយមានការចូលរួម ។

-ដើម្បីឱ្យប្រជាពលរដ្ឋខ្មែរបានយល់ច្បាស់ ហើយនឹងឈានទៅចាត់ទុកថាខ្លួនជាម្ចាស់លើធនធានធម្មជាតិ ។

### គ-ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

#### គ១-ផែនការប្រើប្រាស់ឧបករណ៍នេសាទ

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ គឺរៀបចំឡើងដោយគិតគូរអំពីដែននេសាទ ប្រភេទ ទំហំ ប្រវែង និងចំនួនឧបករណ៍នេសាទ ចំនួនអ្នកនេសាទ និងរដូវនេសាទ។

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ត្រូវបានរៀបចំឡើងដូចខាងក្រោម ៖

| ឈ្មោះ/ទីតាំងកន្លែងនេសាទ | ពេលវេលាធ្វើនេសាទ | ឧបករណ៍នេសាទអនុញ្ញាតឱ្យប្រើ | | | ផ្សេងៗ |
|---|---|---|---|---|---|
| | | ប្រភេទ | ទំហំ/ប្រវែង | ចំនួន | |
| ដែននេសាទកំពង់ត្រឡាច | ពេញ ១ ឆ្នាំ | មងក្តាម | ក្រឡា៦ ស.ម ឡើង/ ៣០០ម៉ែត្រ | ០២ គ្រួសារ | |
| | ពេញ ១ ឆ្នាំ | លបក្តាម | ក្រឡា0.៤x0.៣ម ឡើង/២០០ លប | ១៣ គ្រួសារ | |
| | ខែមករា-ឧសភា | មងត្រីក្បក | ក្រឡា៣,៥ស.មx៤ ស.ម/១០០ ម៉ែត្រ | ៣០ គ្រួសារ | |
| | ខែមេសា ដល់ ខែកក្កដា | ឈិបរុញដៃ | 0.៤មx0.៥ម/១ គ្រឿង | ១០ គ្រួសារ | |
| | ខែមិថុនា ដល់ ខែវិច្ឆិកា | សន្ទូចអូសមឹក | ១០០ផ្លែ | ០៥ គ្រួសារ | |

| | | | | |
|---|---|---|---|---|
| | ពេញ១ឆ្នាំ | សំណាញ់ | ០៦ម | ០២ គ្រួសារ | |
| | ខែមករា ដល់ ខែមិថុនា | ចាប់ក្តាម បង្គា ត្រី ដោយដៃ | | ៣០ គ្រួសារ | |
| | ពេញ១ឆ្នាំ | មងផ្ទោង | ០.២ស.ម/១០០ម | ០៣ គ្រួសារ | |

**គ២-ផែនការបោះបង្គោលព្រំប្រទល់កន្លែងសហគមន៍ និងកន្លែងអភិរក្ស**

ផែនការបោះបង្គោលព្រំប្រទល់កន្លែងសហគមន៍ និងកន្លែងអភិរក្ស នឹងត្រូវបានរៀបចំឡើងដូចខាងក្រោម ៖

| សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|
| ២-១ ប្រជុំពិភាក្សាអំពីការបោះបង្គោលព្រំប្រទល់និងកន្លែងអភិរក្ស | ខែមករា-មីនា ឆ្នាំ២០២១ | ខែមករា-មីនា ឆ្នាំ២០២១ |
| ២-២ ចុះកំណត់ចំណុចទីតាំង | ខែមករា-មីនា ឆ្នាំ២០២១ | ខែមករា-មីនា ឆ្នាំ២០២១ |
| ២.៣ បោះបង្គោលព្រំប្រទល់៤០ដើម | ខែមករា-មីនា ឆ្នាំ២០២១ | ខែមករា-មីនា ឆ្នាំ២០២១ |
| ២.៤ បោះបង្គោលកន្លែងអភិរក្ស១៥ដើម | ខែមេសា-មិថុនា ឆ្នាំ២០២១ | ខែមេសា-មិថុនា ឆ្នាំ ២០២១ |

**គ៣-ផែនការបោះស្លាកសញ្ញានិងប៉ាន់ណូ**

ផែនការបោះស្លាកសញ្ញានិងប៉ាន់ណូ នឹងត្រូវបានរៀបចំឡើងដូចខាងក្រោម ៖

| សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|
| ៣-១ ធ្វើស្លាកសញ្ញាចំនួន២០និងប៉ាន់ណូចំនួន៤ | ខែកក្កដា-កញ្ញា ឆ្នាំ២០២១ | ខែកក្កដា-កញ្ញា ឆ្នាំ២០២១ |
| ៣-២ ចុះកំណត់ទីតាំងបោះ | ខែកក្កដា-កញ្ញា ឆ្នាំ២០២១ | ខែកក្កដា-កញ្ញា ឆ្នាំ២០២១ |
| ៣.៣ បោះស្លាកសញ្ញាចំនួន២០ | ខែកក្កដា-កញ្ញា ឆ្នាំ២០២១ | ខែកក្កដា-កញ្ញា ឆ្នាំ២០២១ |
| ៣.៤ បោះប៉ាន់ណូចំនួន៤ | ខែកក្កដា-កញ្ញា ឆ្នាំ២០២១ | ខែកក្កដា-កញ្ញា ឆ្នាំ២០២១ |

**គ៤-ផែនការពង្រឹងសកម្មភាពល្បាត**

ដើម្បីគ្រប់គ្រង ថែរក្សា ការពារ អភិរក្សធនធានធម្មជាតិ ជាពិសេសធនធានជលផលឲ្យមានភាពល្អប្រសើរ និងមាននិរន្តរភាព សហគមន៍នេសាទមានផែនការពង្រឹងការចុះល្បាតនៅក្នុងកន្លែងនេសាទសហគមន៍ឲ្យបានជាប្រចាំ ។ ផែនការសម្រាប់ពង្រឹងការងារចុះល្បាតឲ្យមានប្រសិទ្ធភាព និងត្រូវបានរៀបចំឡើងដូចខាងក្រោម :

| សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|
| រៀបចំក្រុមល្បាត និងកម្មវិធីល្បាត | ខែមករា ឆ្នាំ២០២១ | ខែមករា ឆ្នាំ២០២៣ |
| បណ្តុះបណ្តាលអំពីនីតិវិធីក្នុងការបង្ក្របបទល្មើស | ខែមករា-មីនា២០២១ | ខែមករា-មីនា២០២១ |
| ទិញប្រេងសាំងសម្រាប់ល្បាតចំនួន២០លីត្រ/ខែ | ខែមករា-ធ្នូ ឆ្នាំ២០២១ | ខែធ្នូ ឆ្នាំ២០២៣ |
| ទិញសម្ភារៈល្បាត | ខែមេសា-មិថុនា ឆ្នាំ២០២១ | ខែមេសា-មិថុនា ឆ្នាំ២០២១ |
| ចុះល្បាត ចំនួន៤ដង/ខែ | ខែមករា ឆ្នាំ២០២១ | ខែធ្នូ ឆ្នាំ២០២៣ |
| ទិញទូកស្នាច់ចំនួន១ទំហំ(៩មx១.៣មx០.៦ម) | ខែមេសា-មិថុនា ឆ្នាំ២០២១ | ខែមេសា-មិថុនា ឆ្នាំ២០២១ |

**គ៥-ផែនការពង្រឹងសមត្ថភាពដល់គណៈកម្មការ និងសមាជិកសហគមន៍**

ផែនការពង្រឹងសមត្ថភាពដល់គណៈកម្មការ និងសមាជិកសហគមន៍ នឹងត្រូវបានរៀបចំឡើងដូចខាងក្រោម ៖

| សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|
| ផ្តល់វគ្គបណ្តុះបណ្តាលចំនួន៤វគ្គក្នុង១ឆ្នាំ | ខែមករា-មិថុនា ឆ្នាំ២០២១ | ខែមករា-មិថុនា ឆ្នាំ២០២៣ |
| ផ្សព្វផ្សាយលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង ផែនការគ្រប់គ្រង និងលិខិតបទដ្ឋានផ្សេងៗដល់សមាជិកចំនួន១២ដងក្នុងឆ្នាំ | ខែមករា ឆ្នាំ២០២១ | ខែធ្នូ ឆ្នាំ២០២៣ |

**គ៦-ផែនការពង្រីក និងបន្ថែមមុខរបរចិញ្ចឹមជីវិត**

ផែនការពង្រីកនិងបន្ថែមមុខរបរចិញ្ចឹមជីវិត និងត្រូវបានរៀបចំឡើងដូចខាងក្រោម ៖

| ប្រភេទ | ចំនួន | ប្រភេទកូនពូជ | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|
| ចិញ្ចឹមត្រីអណ្តែង | ចំនួន៥គ្រួសារ | ៥០០ក្បាល/១គ្រួសារ | ខែកក្កដា-កញ្ញា ឆ្នាំ ២០២១ | ខែកក្កដា-កញ្ញា ឆ្នាំ ២០២១ |
| ចិញ្ចឹមត្រីឆ្ពួញ | ចំនួន៥គ្រួសារ | ១០០០ក្បាល/១គ្រួសារ | ខែកក្កដា-កញ្ញា ឆ្នាំ ២០២១ | ខែកក្កដា-កញ្ញា ឆ្នាំ ២០២១ |
| ចិញ្ចឹមអន្ទង់ | ចំនួន២គ្រួសារ | ៥០០ក្បាល/១គ្រួសារ | ខែកក្កដា-កញ្ញា ឆ្នាំ ២០២១ | ខែកក្កដា-កញ្ញា ឆ្នាំ ២០២១ |
| ចិញ្ចឹមមាន់ | ចំនួន១០គ្រួសារ | មេមាន់៣ និងឈ្មោល ១/គ្រួសារ | ខែតុលា-ធ្នូ ឆ្នាំ២០២១ | ខែតុលា-ធ្នូ ឆ្នាំ២០២១ |

**គ៧-ផែនការសាងសង់ស្នាក់សហគមន៍**

ផែនការសាងសង់ស្នាក់ការសហគមន៍ នឹងត្រូវបានរៀបចំឡើងដូចខាងក្រោម ៖

| សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|
| ប្រជុំបង្កើតប្លង់ស្នាក់ការ | ខែមករា-មីនា ឆ្នាំ២០២២ | ខែមីនា ឆ្នាំ២០២២ |
| សម្រង់តម្លៃ | ខែមករា-មីនា ឆ្នាំ២០២២ | ខែមករា-មីនា ឆ្នាំ២០២២ |
| សាងសង់ស្នាក់ទំហំ(៥មx៦ម) ឈើលាយស័ង្កសី | ខែមេសា-មិថុនា ឆ្នាំ២០២២ | ខែមេសា-មិថុនា ឆ្នាំ២០២២ |
| សាងសង់បន្ទប់ទឹកចំនួន២ទំហំ(២មx២ម) | ខែមេសា-មិថុនា ឆ្នាំ២០២២ | ខែមេសា-មិថុនា ឆ្នាំ២០២២ |
| ទិញធុងទឹកចំនួន២ | ខែមេសា-មិថុនា ឆ្នាំ២០២២ | ខែមេសា-មិថុនា ឆ្នាំ២០២២ |

**គ៨-ផែនការរកប្រាក់ចំណូលសម្រាប់សហគមន៍**

ផែនការរកប្រាក់ចំណូលសម្រាប់សហគមន៍ នឹងត្រូវបានរៀបចំឡើងដូចខាងក្រោម ៖

| សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|
| ចុះប្រមូលវិភាគទានប្រចាំឆ្នាំតាមគ្រួសារ | ខែតុលា-ធ្នូ២០២១ | ខែតុលា-ធ្នូ២០២៣ |
| រៀបចំប្រអប់មូលនិធិទ្រទ្រង់សហគមន៍ | ខែមករា-មីនា ឆ្នាំ២០២១ | ខែមករា-មីនា ឆ្នាំ២០២១ |

ឃ-យុទ្ធសាស្ត្រ

ដើម្បីអនុវត្តផែនការឱ្យទទួលបានជោគជ័យ យុទ្ធសាស្ត្រមួយចំនួនត្រូវបានរៀបចំ ដូចខាងក្រោម ៖

-បង្កើតគណៈកម្មការសម្រាប់អនុវត្តតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការរួមមាន សមាជិកគណៈកម្មការសហគមន៍នេសាទ ចាស់ទុំដែលមានបទពិសោធន៍និងចំណេះដឹងល្អៗជាពិសេសបញ្ហានេសាទ។

-ស្នើសុំជំនួញបច្ចេកទេសពីរដ្ឋបាលជលផលមានសមត្ថកិច្ច ដើម្បីជួយផ្តល់យោបល់ចំពោះផែនការណា ដែលទាក់ទងនិងបច្ចេកទេសជលផលដូចជា ការធ្វើផែនការកន្លែងអភិរក្សមេពូជត្រី ការរៀបចំកន្លែងអភិរក្សព្រៃលិចទឹក កន្លែងអភិរក្សជីវៈចម្រុះ ការកំណត់ឧបករណ៍នេសាទ ការចិញ្ចឹមត្រី ការរកថវិកាទ្រទ្រង់ជាដើម ។

-រៀបចំយុទ្ធសាស្ត្រទំនាក់ទំនងជាមួយស្ថាប័នជំនាញ អង្គការនានា គម្រោង និងម្ចាស់ជំនួយដើម្បីទទួលបានការឧបត្ថម្ភគាំទ្រ និងថវិការសម្រាប់ដំណើរការអនុវត្តផែនការ ។

-រៀបចំផែនការអនុវត្តផែនការតាមដំណាក់កាលនិមួយៗដោយជាក់លាក់ ។

-ទាក់ទងជាមួយរដ្ឋបាលជលផលដើម្បីសុំការគាំទ្រថវិកា និងជួយរកដៃគូសម្រាប់ទ្រទ្រង់ផែនការគ្រប់គ្រងសហគមន៍នេសាទ ។

-ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ដល់សមាជិកសហគមន៍នេសាទ និងអ្នកពាក់ព័ន្ធសំខាន់ៗ ដើម្បីជម្រុញការចូលរួម និងគាំទ្រដល់ការអនុវត្តផែនការគ្រប់គ្រងនេះ ។

-កៀងគរការចូលរួមចំណែករបស់សមាជិកសហគមន៍នេសាទ ។

-រៀបចំវិធានការណ៍ចំពោះអ្នកនេសាទមកពីខាងក្រៅសហគមន៍ ។

-ពង្រឹងសមត្ថភាពបច្ចេកទេស និង គ្រប់គ្រងរបស់គណៈកម្មការសហគមន៍នេសាទ ។

-ចងក្រងក្រុមអ្នកនេសាទទៅតាមប្រភេទឧបករណ៍នេសាទ ដើម្បីចូលរួមអនុវត្តផែនការ ។

-បញ្ចូលផែនការគ្រប់គ្រងសហគមន៍នេសាទទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ។

## តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍កំពង់ត្រឡាចរយៈពេល ០៣ឆ្នាំ (២០២១ ដល់ ២០២៣)

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានចំណាយ(រៀល) | ប្រភពជំនួយ | ពេលចាប់ផ្តើម | ពេលបញ្ចប់ |
|---|---|---|---|---|---|---|
| ១.ការប្រើប្រាស់ឧបករណ៍នេសាទក្នុងដែននេសាទសហគមន៍ | ១.១ រៀបចំឯកសារផ្សព្វផ្សាយ | -ផលស្តុកមាននិរន្តរភាពក្នុងសហគមន៍ | ២០០,០០០ | | ខែមករា-មីនា ឆ្នាំ២០២១ | ខែមករា-មីនា ឆ្នាំ២០២៣ |
| | ១.២ ផ្សព្វផ្សាយដល់សមាជិកសហគមន៍នេសាទចំនួន២ដងក្នុង១ឆ្នាំ | | ១,២០០,០០០ | | ខែមករា-មីនា ឆ្នាំ២០២១ | ខែមករា-មីនា ឆ្នាំ២០២៣ |
| ២-ផែនការបោះបង្គោលព្រំប្រទល់កន្លែងសហគមន៍ និងកន្លែងអភិរក្ស | ២-១ ប្រជុំពិភាក្សាអំពីការបោះបង្គោលព្រំប្រទល់និងកន្លែងអភិរក្ស | -ធនធានជលផលនឹងកើនឡើង<br>-ប្រជាពលរដ្ឋមានការយល់ដឹងពិសារៈប្រយោជន៍កន្លែងអភិរក្ស<br>-កន្លែងអភិរក្សត្រូវបានបង្កើត | ១០០,០០០ | | ខែមករា-មីនា ឆ្នាំ២០២១ | ខែមករា-មីនា ឆ្នាំ២០២១ |
| | ២-២ ចុះកំណត់ចំណុចទីតាំង | | ៨០០,០០០ | | ខែមករា-មីនា ឆ្នាំ២០២១ | ខែមករា-មីនា ឆ្នាំ២០២១ |
| | ២-៣ បោះបង្គោលព្រំប្រទល់សហគមន៍ចំនួន៤០ដើម | | ២៤,០០០,០០០ | | ខែមករា-មីនា ឆ្នាំ២០២១ | ខែមករា-មីនា ឆ្នាំ២០២១ |
| | ២-៤ បោះបង្គោលកន្លែងអភិរក្សចំនួន១៥ដើម | | ១២,០០០,០០០ | | ខែមេសា-មិថុនា ឆ្នាំ២០២១ | ខែមេសា-មិថុនា ឆ្នាំ២០២១ |
| ៣-ផែនការបោះស្លាកសញ្ញានិងប៉ាន់ណូ | ៤-១ ធ្វើស្លាកសញ្ញាចំនួន២០ និងប៉ាន់ណូចំនួន៤ | -ប្រជាពលរដ្ឋមានការយល់ដឹងអំពីទីតាំងសហគមន៍ច្បាស់លាស់ | ៨,០០០,០០០ | | ខែកក្កដា-កញ្ញា ឆ្នាំ២០២១ | ខែកក្កដា-កញ្ញា ឆ្នាំ២០២១ |
| | ៤-២ ចុះកំណត់ទីតាំងបោះ | | ៤០០,០០០ | | ខែកក្កដា-កញ្ញា ឆ្នាំ២០២១ | ខែកក្កដា-កញ្ញា ឆ្នាំ២០២១ |
| | ៤-៣ បោះស្លាកសញ្ញា២០ | | ២,៤០០០,០០ | | ខែកក្កដា-កញ្ញា ឆ្នាំ២០២១ | ខែកក្កដា-កញ្ញា ឆ្នាំ២០២១ |
| | ៤-៤ បោះប៉ាន់ណូ៤ | | ៥,៦០០,០០០ | | ខែកក្កដា-កញ្ញា ឆ្នាំ២០២១ | ខែកក្កដា-កញ្ញា ឆ្នាំ២០២១ |
| ៤-ផែនការល្បាតទប់ស្កាត់បទល្មើសនេសាទ | ៤-១ រៀបចំក្រុមល្បាត និងកម្មវិធីល្បាត | -បទល្មើសជលផលមានការថយចុះ | ៨០,០០០ | | ខែមករា ឆ្នាំ២០២១ | ខែមករា ឆ្នាំ២០២១ |

| | | | | | | |
|---|---|---|---|---|---|---|
| | ៤-២ បណ្តុះបណ្តាលអំពី នីតិវិធី ក្នុងការបង្រ្កាបបទល្មើស | -ក្រុមល្បាតបានយល់ដឹងពី នីតិ វិធីទប់ស្កាត់ល្មើស<br>-ធនធានមាននិរន្តភាព | ៣,២០០,០០០ | | ខែមករា-មីនា ២០២១ | ខែមករា-មីនា ២០២១ |
| | ៤.៣ ទិញប្រេងសាំងសម្រាប់ល្បាតចំនួន២០លីត្រ/ខែ | | ២,៨៨០,០០០ | | ឆ្នាំ២០២១ | ឆ្នាំ២០២៣ |
| | ៤.៤ ទិញសម្ភារៈល្បាត | | ៦៨០,០០០ | | ខែមេសា-មិថុនា ឆ្នាំ២០២១ | ខែមេសា-មិថុនា ឆ្នាំ២០២១ |
| | ៤.៥ ចុះល្បាតចំនួន៤ដង/ខែ | | ០ | | ឆ្នាំ២០២១ | ឆ្នាំ២០២៣ |
| | ៤.៦ ទិញទូកស្នាច់ចំនួន១ទំហំ(៩មx ១.៣មx០.៦ម) | | ៨,០០០,០០០ | | ខែមេសា-មិថុនា ឆ្នាំ២០២១ | ខែមេសា-មិថុនា ឆ្នាំ២០២១ |
| | ៤-៧ ប្រជុំបូកសរុបការងារប្រចាំខែជាមួយជលផលនិងអាជ្ញាធរមូលដ្ឋាន | | ២,៨៨០,០០០ | | ឆ្នាំ២០២១ | ឆ្នាំ២០២៣ |
| ៥.ផែនការពង្រឹងសមត្ថភាពគណៈកម្មការនិងសមាជិកសហគមន៍ | ៥.១ ផ្តល់វគ្គបណ្តុះបណ្តាលចំនួន៤វគ្គក្នុង១ឆ្នាំ | -សហគមន៍មានសមត្ថភាពក្នុងការដឹកនាំនិងគ្រប់គ្រង<br>-សមាជិកសហគមន៍មានការយល់ដឹងពីលិខិតបដ្ឋានផ្សេងៗ | ៤៨,០០០,០០០ | | ខែមករា-មិថុនា ឆ្នាំ២០២១ | ខែមករា-មិថុនា ឆ្នាំ២០២៣ |
| | ៥.២ ផ្សព្វផ្សាយលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង ផែនការគ្រប់គ្រង និងលិខិតបទដ្ឋានផ្សេងៗដល់សមាជិកចំនួន១២ដងក្នុងឆ្នាំ | | ២១,០០០,០០០ | | ឆ្នាំ២០២១ | ឆ្នាំ២០២៣ |
| ៦-ផែនការពង្រីក និងបន្ថែមមុខរបរចិញ្ចឹមជីវិត | ៦-១ ផ្តល់ពូជចិញ្ចឹមត្រីអណ្តែង០៥គ្រួសារ | -ប្រជាជនមានជីវភាពប្រសើរឡើង | ២,៥០០,០០០ | | ខែកក្កដា-កញ្ញា ឆ្នាំ២០២១ | ខែកក្កដា-កញ្ញា ឆ្នាំ២០២១ |
| | ៦-២ ផ្តល់ពូជចិញ្ចឹមត្រីឆ្លូញ០៥គ្រួសារ | | ២,៥០០,០០០ | | ខែកក្កដា-កញ្ញា ឆ្នាំ២០២១ | ខែកក្កដា-កញ្ញា ឆ្នាំ២០២១ |
| | ៦.៣ ផ្តល់ពូជចិញ្ចឹមអន្ទង់ចំនួន០២គ្រួសារ | | ២,៥០០,០០០ | | ខែកក្កដា-កញ្ញា ឆ្នាំ២០២១ | ខែកក្កដា-កញ្ញា ឆ្នាំ២០២១ |
| | ៦-៤ ផ្តល់ពូជចិញ្ចឹមមាន់ចំនួន១០គ្រួសារ | | ២,០០០,០០០ | | ខែតុលា-ធ្នូ ឆ្នាំ ២០២១ | ខែតុលា-ធ្នូ ឆ្នាំ ២០២១ |
| ៧-ផែនការសាងសង់ស្នាក់ការ | ៧.១ ប្រជុំបង្កើតប្លង់ស្នាក់ការ | -សហគមន៍នឹងមានទីកន្លែងធ្វើការច្បាស់លាស់ | ៨០,០០០ | | ខែមករា-មីនា ឆ្នាំ ២០២២ | ខែមករា-មីនា ឆ្នាំ ២០២២ |

| | | | | | | |
|---|---|---|---|---|---|---|
| | ៧.២ សម្រង់តម្លៃ | | 0 | | ខែមករា-មីនា ឆ្នាំ ២០២២ | ខែមករា-មីនា ឆ្នាំ ២០២២ |
| | ៧.៣ សាងសង់ស្នាក់ការឈើ ប្រក់ស័ង្កសី | | ១៤,000,000 | | ខែមេសា-មិថុនា ឆ្នាំ២០២២ | ខែមេសា-មិថុនា ឆ្នាំ២០២២ |
| | ៧.៤ សាងសង់បន្ទប់ទឹកចំនួន០២ | | ២,៨00,000 | | ខែមេសា-មិថុនា ឆ្នាំ២០២២ | ខែមេសា-មិថុនា ឆ្នាំ២០២២ |
| | ៧.៥ ទិញធុងទឹកចំនួន០២ | | ៨00,000 | | ខែមេសា-មិថុនា ឆ្នាំ២០២២ | ខែមេសា-មិថុនា ឆ្នាំ២០២២ |
| ៨.ផែនការរកប្រាក់ចំណូលចូលសហគមន៍ | ៨.១ ប្រមូលវិភាគទានប្រចាំឆ្នាំរបស់សមាជិក | -សហគមន៍នឹងមានចំណូលក្នុងការអភិវឌ្ឍន៍សហគមន៍ | ១00,000 | | ខែតុលា-ធ្នូ ២០២១ | ខែតុលា-ធ្នូ ២០២៣ |
| | ៨.២ រៀបចំប្រអប់មូលនិធិទ្រទ្រង់សហគមន៍នេសាទ | | ៤00,000 | | ខែមករា-មីនា ឆ្នាំ ២០២១ | ខែមករា-មីនា ឆ្នាំ ២០២១ |
| **សរុបចំណាយរួម** | | | **១៦៦,៧00,000** | | | |

# តារាងកម្មវិធីការងារ

| សកម្មភាព | ពេលវេលា | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០២១ | | | | | | | | | | | | ២០២២ | | | | | | | | | | | | ២០២៣ | | | | | | | | | | | |
| | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ |
| **១-ផែនការប្រើប្រាស់ឧបករណ៍នេសាទ** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ១.១ រៀបចំឯកសារផ្សព្វផ្សាយ | ■ | ■ | ■ | | | | | | | | | | ■ | ■ | ■ | | | | | | | | | | ■ | ■ | ■ | | | | | | | | | |
| ១.២ផ្សព្វផ្សាយដល់សមាជិកសហគមន៍នេសាទចំនួន២ដងក្នុង១ឆ្នាំ | ■ | ■ | ■ | | | | | | | | | | ■ | ■ | ■ | | | | | | | | | | ■ | ■ | ■ | | | | | | | | | |
| **២-ផែនការបោះបង្គោលព្រំប្រទល់កន្លែងសហគមន៍ និងកន្លែងអភិរក្ស** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ២-១ ប្រជុំពិភាក្សាអំពីការបោះបង្គោលព្រំប្រទល់និងកន្លែងអភិរក្ស | ■ | ■ | ■ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ២-២ ចុះកំណត់ចំណុចទីតាំង | ■ | ■ | ■ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ២-៣ បោះបង្គោលព្រំប្រទល់សហគមន៍ចំនួន៤០ដើម | ■ | ■ | ■ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ២-៤ បោះបង្គោលកន្លែងអភិរក្សចំនួន១៥ដើម | | | | ■ | ■ | ■ | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| **៣-ផែនការបោះស្លាកសញ្ញានិងប៉ាន់ណូ** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៣-១ ធ្វើស្លាកសញ្ញាចំនួន២០និងប៉ាន់ណូចំនួន៤ | | | | | | | ■ | ■ | ■ | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៣-២ ចុះកំណត់ទីតាំងបោះ | | | | | | | ■ | ■ | ■ | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៣-៣ បោះស្លាកសញ្ញា២០ | | | | | | | ■ | ■ | ■ | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៣-៤ បោះប៉ាន់ណូ៤ | | | | | | | ■ | ■ | ■ | | | | | | | | | | | | | | | | | | | | | | | | | | | |

| | |
|---|---|
| **៤-ផែនការល្បាតទប់ស្កាត់បទល្មើសនេសាទ** | |
| ៤-១ រៀបចំក្រុមល្បាត និងកម្មវិធីល្បាត | |
| ៤-២ បណ្តុះបណ្តាលអំពី នីតិវិធីក្នុងការបង្ក្រាបបទល្មើស | |
| ៤.៣ ទិញប្រេងសាំងសម្រាប់ល្បាតចំនួន២០លីត្រ/ខែ | |
| ៤.៤ ទិញសម្ភារៈល្បាត | |
| ៤.៥ ចុះល្បាតចំនួន៤ដង/ខែ | |
| ៤.៦ ទិញទូកស្នាច់ចំនួន១ទំហំ (៩មx១.៣មx០.៦ម) | |
| ៤-៧ ប្រជុំបូកសរុបការងារប្រចាំខែជាមួយជលផលនិងអាជ្ញាធរមូលដ្ឋាន | |
| **៥-ផែនការពង្រឹងសមត្ថភាពគណៈកម្មការនិងសមាជិកសហគមន៍** | |
| ៥.១ ផ្តល់វគ្គបណ្តុះបណ្តាលចំនួន៤វគ្គក្នុង១ឆ្នាំ | |
| ៥.២ ផ្សព្វផ្សាយលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង ផែនការគ្រប់គ្រង និងលិខិតបទដ្ឋានផ្សេងៗដល់សមាជិកចំនួន១២ដងក្នុងឆ្នាំ | |
| **៦-ផែនការពង្រីក និងបន្ថែមមុខរបរចិញ្ចឹមជីវិត** | |
| ៦-១ ផ្តល់ពូជចិញ្ចឹមត្រីអណ្តែង ០៥ គ្រួសារ | |
| ៦-២ ផ្តល់ពូជចិញ្ចឹមត្រីឆ្ពង់០៥ គ្រួសារ | |

| | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ៦.៣ ផ្តល់ពូជចិញ្ចឹមអន្ទង់ចំនួន ០២គ្រួសារ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៦-៤ ផ្តល់ពូជចិញ្ចឹមមាន់ចំនួន ១០គ្រួសារ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| **៧-ផែនការសាងសង់ស្នាក់ការ** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៧.១ ប្រជុំបង្កើតប្លង់ស្នាក់ការ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៧.២ សម្រង់តម្លៃ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៧.៣ សាងសង់ស្នាក់ការឈើប្រក់ស័ង្កសី | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៧.៤ សាងសង់បន្ទប់ទឹកចំនួន ០២ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៧.៥ ទិញធុងទឹកចំនួន០២ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| **៨-ផែនការរកប្រាក់ចំណូលចូលសហគមន៍** | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៨.១ ប្រមូលវិភាគទានប្រចាំឆ្នាំរបស់សមាជិក | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| ៨.២ រៀបចំប្រអប់មូលនិធិទ្រទ្រង់សហគមន៍ | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |

បានឃើញ និងគោរពជូន
លោកនាយផ្នែករដ្ឋបាលជលផលដំណាក់ស្ដេច
" ដើម្បីជូនពិនិត្យ និងសម្រួល"
ថ្ងៃ ខែ ឆ្នាំ ជូត ទោស័ក ព.ស ២៥៦៤
ថ្ងៃទី ខែ ឆ្នាំ២០២០
**នាយសង្កាត់រដ្ឋបាលជលផលអូរក្រសា**

លេខ.................
បានឃើញ និងគោរពជូន
លោកនាយសង្កាត់រដ្ឋបាលជលផលអូរក្រសា
" ដើម្បីជូនពិនិត្យ និងសម្រួល"
ថ្ងៃ ខែ ឆ្នាំ ជូត ទោស័ក ព.ស ២៥៦៤
ថ្ងៃទី ខែ ឆ្នាំ២០២០
**សង្កាត់ព្រៃធំ**

**គុច សារ៉េន**

សូមគោរពជូន
លោកចៅសង្កាត់ព្រៃធំ
" ដើម្បីជូនពិនិត្យ និងសម្រួល"
ថ្ងៃ ខែ ឆ្នាំ ជូត ទោស័ក ព.ស ២៥៦៤
ថ្ងៃទី ៤ ខែ ឆ្នាំ២០២០
**ប្រធានគណៈកម្មការសហគមន៍នេសាទកំពង់ត្រឡាច**

លេខ :................
បានឃើញ និងគោរពជូន
ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាប្រធានរដ្ឋបាលជលផល
" ដើម្បីជូនពិនិត្យ និងសម្រេចដោយអនុគ្រោះ"
ថ្ងៃ ខែ ឆ្នាំ ជូត ទោស័ក ព.ស ២៥៦៤
ថ្ងៃទី ១០ ខែ ឆ្នាំ២០២០
**ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកែប**

លេខ :................
បានឃើញ និងគោរពជូន
លោកប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកែប
" ដើម្បីជូនពិនិត្យ និងសម្រួល"
ថ្ងៃ ខែ ឆ្នាំ ជូត ទោស័ក ព.ស ២៥៦៤
ថ្ងៃទី ០៧ ខែ ឆ្នាំ២០២០
**នាយខណ្ឌរដ្ឋបាលជលផលកែប**

**គុជ ទិរៈ**

បានឃើញ និងគោរពជូន
លោកនាយខណ្ឌរដ្ឋបាលជលផលកែប
" ដើម្បីជូនពិនិត្យ និងសម្រួល"
ថ្ងៃ ខែ ឆ្នាំ ជូត ទោស័ក ព.ស ២៥៦៤
ថ្ងៃទី ០៧ ខែ ឆ្នាំ២០២០
**នាយផ្នែករដ្ឋបាលជលផលដំណាក់ស្ដេច**

លេខ :................
បានឃើញ និងឯកភាព
ថ្ងៃ ខែ ឆ្នាំ ជូត ទោស័ក ព.ស ២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ឆ្នាំ២០២០
**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា**
**ប្រធានរដ្ឋបាលជលផល**

**ទិត_បុរិន**